ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

*ថ្ងៃ ព្រហស្បតិ៍ ៤ កើត ខែ ជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣*
*រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១៩*

# សេចក្តីប្រកាសព័ត៌មានស្តីពី
# ជំនួបពិភាក្សាការងាររវាងឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាមួយឯកឧត្តម Ivo Sieber ឯកអគ្គរដ្ឋទូតសហព័ន្ធស្វីសប្រចាំនៅកម្ពុជា

នាព្រឹកថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១៩, នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានទទួលជួបពិភាក្សាការងារជាមួយឯកឧត្តម Ivo Sieber ឯកអគ្គរដ្ឋទូតសហព័ន្ធស្វីសប្រចាំនៅកម្ពុជា ក្នុងខណៈពេលដែលឯកឧត្តមឯកអគ្គរដ្ឋទូតត្រូវបញ្ចប់អាណត្តិបេសកកម្មការទូតរបស់ឯកឧត្តមនៅកម្ពុជា ។

ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** បានសម្តែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះសមិទ្ធិផលការងារទាំងឡាយដែលកើតពីការខិតខំប្រឹងប្រែងទាំងកម្លាំងកាយ និងកម្លាំងចិត្តរបស់ឯកឧត្តម Ivo Sieber ក្នុងអាណត្តិការងារការទូតរបស់ឯកឧត្តមនៅកម្ពុជា ដែលបានធ្វើឱ្យទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការទ្វេភាគីកម្ពុជា-ស្វីស កាន់តែរឹងមាំ និងស៊ីជម្រៅ ពិសេស កិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម, សេដ្ឋកិច្ច និងការអភិវឌ្ឍនានានៅកម្ពុជា ។ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ក៏បានសម្តែងនូវអំណរគុណដល់រដ្ឋាភិបាលស្វីសដែលបន្តគាំទ្រ និងជួយដល់កិច្ចដំណើរការរបស់មន្ទីរពេទ្យគន្ធបុប្ផា ដែលតាមរយៈទីភ្នាក់ងារស្វីសសម្រាប់ការអភិវឌ្ឍ និងសហប្រតិបត្តិការ រដ្ឋាភិបាលស្វីស បានសន្យាបន្តចូលរួមចំណែកគាំទ្រផ្នែកហិរញ្ញវត្ថុដល់មន្ទីរពេទ្យសម្រាប់រយៈពេល ០៤ ឆ្នាំ ទៅមុខទៀត ។ ជាមួយគ្នានេះ, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** បានគូសបញ្ជាក់បន្ថែមថា រាជរដ្ឋាភិបាលកម្ពុជា ក៏បានខិតខំយ៉ាងមុតមាំក្នុងការគាំទ្រកិច្ចដំណើរការរបស់មន្ទីរពេទ្យនេះ តាមរយៈការបង្កើត "**មូលនិធិគន្ធបុប្ផាកម្ពុជា**" ក្រោមគំនិតផ្តួចផ្តើមដ៏ខ្ពង់ខ្ពស់របស់សម្តេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីកៀរគរធនធានសំដៅធានាចីរភាពនៃកិច្ចដំណើរការរបស់មន្ទីរពេទ្យគន្ធបុប្ផាកម្ពុជានេះ ។

ឯកឧត្តម Ivo Sieber បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រសួង-ស្ថាប័នពាក់ព័ន្ធរបស់កម្ពុជា ដែលបានផ្តល់កិច្ចសហប្រតិបត្តិការយ៉ាងល្អប្រសើរ ដែលបានជំរុញឱ្យបេសកកម្មការទូតជាង ៤ ឆ្នាំ កន្លងទៅរបស់ឯកឧត្តមនៅកម្ពុជា ទទួលបានជោគជ័យដ៏ត្រចះត្រចង់ ។ ឯកឧត្តមឯកអគ្គរាជទូត បានឃើញពីការរីកចម្រើនឥតឈប់ឈររបស់កម្ពុជានាពេលបច្ចុប្បន្ន ជាមួយកំណើនសេដ្ឋកិច្ចរឹងមាំ ដែលកើតចេញពីការខិតខំប្រឹងប្រែងកែទម្រង់លើគ្រប់វិស័យ និងដឹកនាំប្រាកដនិយមរបស់រាជរដ្ឋាភិបាលកម្ពុជា ។ ជាមួយនឹងបទពិសោធន៍ការងារយ៉ាងច្រើនក្រាស់ក្រែលនៅកម្ពុជា ឯកឧត្តមផ្ទាល់នៅតែមានអារម្មណ៍ស្និតស្នាលជាមួយកម្ពុជាជានិច្ច ។

ក្នុងជំនួបពិភាក្សានេះដែរ ភាគីទាំងពីរបានឯកភាព ជំរុញលើកកម្ពស់ការវិនិយោគ ធ្វើឱ្យកាន់តែទូលំទូលាយនូវទំហំពាណិជ្ជកម្មរវាងប្រទេសទាំងពីរ តាមរយៈ ការលើកទឹកចិត្តអ្នកវិនិយោគិនស្វីសឱ្យមកអោយមកបណ្តាក់ទុននៅកម្ពុជា ប្រកបដោយភាពជឿជាក់ ដោយកម្ពុជា បាន និងកំពុងរៀបចំបរិយាកាសធុរកិច្ចអំណោយផលដល់អ្នកវិនិយោគិនបរទេសគ្រប់រូប និងខិតខំរៀបចំកែទម្រង់លើគ្រប់វិស័យដើម្បីកសាងបាននូវភាពប្រកួតប្រជែងកាន់តែប្រសើរជាមុន ។

ជាចុងបញ្ចប់, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** បានជូនពរឯកឧត្តម Ivo Sieber ឱ្យទទួលបានជោគជ័យក្នុងតួនាទីថ្មីរបស់ឯកឧត្តម និងបានបញ្ជាក់ថា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បន្តរក្សាវីតចំណងទំនាក់ទំនងល្អជាមួយឯកអគ្គរដ្ឋទូតថ្មីរបស់សហព័ន្ធស្វីស លើកកម្ពស់កិច្ចសហប្រតិបត្តិការ និងមិត្តភាពឱ្យកាន់តែស្អិតរមួតបន្ថែមទៀត ដើម្បីជាឧត្តមប្រយោជន៍សម្រាប់ប្រទេស និងប្រជាជននៃប្រទេសទាំងពីរ កម្ពុជា- ស្វីស ។